គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៤៤ ចេញផ្សាយថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២
No. 44 Released on May 2, 2022

អត្ថបទប្រចាំសប្ដាហ៍ | Weekly Article

# តើប្រតិបត្តិការបរធនបាលកិច្ចត្រូវបានបង្កើតឡើងយ៉ាងដូចម្ដេចនៅកម្ពុជា និងតាំងពីពេលណាមក?

# How was the Trust Operation Established in Cambodia and Since When?

ប្រតិបត្តិការបរធនបាលកិច្ចត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨ តាមរយៈការគិតគូររៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងគោលបំណងគ្រប់គ្រងមូលនិធិហិរញ្ញប្បទានឥតសំណង ឬអនុបំណុលដែលដៃគូអភិវឌ្ឍន៍ផ្ដល់ឱ្យរាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យធនាគារ និងវិស័យមីក្រូហិរញ្ញវត្ថុ ដែលមូលនិធិទាំងនោះត្រូវបានគ្រប់គ្រងនិងចាត់ចែងប្រើប្រាស់ដោយគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។

តាមរយៈការគិតគូររៀបចំគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំជាសេចក្ដីព្រាងច្បាប់ស្ដីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងបានដាក់ឆ្លងអង្គប្រជុំអន្តរក្រសួងបានម្ដង ប៉ុន្តែត្រូវដកយកមកពិនិត្យរៀបចំឡើងវិញ ដើម្បីពង្រីកវិសាលភាពឱ្យកាន់តែទូលំទូលាយ។

សម្រាប់ដំណើរការការងារបណ្ដោះអាសន្ន ដើម្បីឆ្លើយតបនឹងសេចក្ដីត្រូវការចាំបាច់ក្នុងការគ្រប់គ្រងលើមូលនិធិនានាដែលត្រូវបានផ្ដល់ឱ្យរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានស្នើក្នុងក្របខណ្ឌច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ រៀបចំអនុក្រឹត្យស្ដីពីបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣។ នៅក្នុងដំណាក់កាលនៃការអនុវត្តបណ្ដោះអាសន្ន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមាននាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ បានទទួលស្គាល់ជាផ្លូវការនូវការចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុចំនួន ៩ ដែលមានទំហំសមតុល្យបរធនដើមគ្រាប្រមាណ ១១៤,៨០៨,១២៣ ដុល្លារអាមេរិក ហើយរហូតមកដល់ពេលនេះមានទំហំសមតុល្យបរធនប្រមាណ ១៥៥ លានដុល្លារអាមេរិក។

The trust operation was established in 2008 with the initiation of the Ministry of Economy and Finance as the staff for the Royal Government in order to manage the grant funds or sub-debt that the development partners provided to the Royal Government to support the development of the banking and microfinance sector where those funds are managed and administered by banking and microfinance institutions.

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia www.trustregulator.gov.kh (855) 23 237 888
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

The Ministry of Economy and Finance prepared the first draft law on financial trust and this draft law was once submitted to the inter-ministerial meeting, but was withdrawn for revision to expand its scope.

For the temporary work in response to the urgent need for managing the funds granted to the Royal Government, the Ministry of Economy and Finance proposed in the framework of the Law on Financial Management for the year 2013 and prepared a sub-decree on financial trust launched on August 26, 2013. In the interim implementation phase, the Ministry of Economy and Finance, with the Department of Market and Financial Institutions of the General Department of Financial Industry, has officially recognized 9 financial trust registrations, with the size of the beginning balance of trust fund, approximately USD114,808,123, and with the current balance, approximately USD 155 million.

អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.